**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ៥៦៨ សហវ.ប្រក.

# ប្រកាស
# ស្តីពី
# អាករសម្រាប់បំភ្លឺសាធារណៈ

## ឧបនាយករដ្ឋមន្ត្រី
## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២៣/០០១ ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០២៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥២៣/០០៤ ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០២៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសារពើពន្ធ
- បានឃើញអនុក្រឹត្យលេខ ៤៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ២៨៦ អនក្រ.បក ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៣ ស្តីពីអាករសម្រាប់បំភ្លឺសាធារណៈ
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA
mef.gov.kh
t.me/mefcambodia
ទូរស័ព្ទ: (+៨៥៥)២៣ ៨៩០ ៦៦៦
Phone: (+855) 23 890 666
info@mef.gov.kh
mef.cabinet@mef.gov.kh

## សម្រេច

**ប្រការ១ .-**

ប្រកាសនេះ មានគោលបំណងកំណត់នូវវិធាននិងនីតិវិធីនៃការគ្រប់គ្រងប្រមូលអាករសម្រាប់បំភ្លឺសាធារណៈ។

**ប្រការ២ .-**

ប្រកាសនេះ មានវិសាលភាពអនុវត្តចំពោះការផ្គត់ផ្គង់ផលិតផលសុរា មេរ័យ ឬថ្នាំជក់ក្នុងព្រះរាជាណាចក្រកម្ពុជា។

**ប្រការ៣ .-**

សម្រាប់គោលដៅនៃប្រកាសនេះ៖

១- ផលិតផលជាប់អាករ សំដៅដល់ សុរា មេរ័យ ឬថ្នាំជក់។ សម្រាប់គោលដៅនៃកថាខណ្ឌនេះ៖

ក- សុរា សំដៅដល់ ផលិតផលគ្រប់ប្រភេទដែលមានជាតិអាល់កុល លើកលែងតែផលិតផលអាល់កុលដែលប្រើក្នុងវិស័យវេជ្ជសាស្ត្រ។

ខ- មេរ័យ សំដៅដល់ ទឹកស្រវឹងដែលធ្វើឡើងដោយការត្រាំគ្រឿងផ្សំផ្សេងៗ មានជាអាទិ៍ ស្រាបៀរ ឬភេសជ្ជៈមានជាតិស្រវឹង លើកលែងតែទឹកត្នោតជូរ និងស្រាស ដែលផលិតដោយមិនមានការកែច្នៃរក្សាគុណភាព និង/ឬវេចខ្ចប់ តាមរូបភាពសិប្បកម្ម ឬឧស្សាហកម្ម។

គ- ថ្នាំជក់ សំដៅដល់ ផលិតផលទាំងមូលឬមួយផ្នែកដែលផ្សំឡើងដោយស្លឹកថ្នាំជក់ ឬសារធាតុថ្នាំជក់ ឬសារធាតុផ្សេងៗទៀតជាវត្ថុធាតុដើម ដែលផលិតសម្រាប់យកទៅជក់ មានជាអាទិ៍ បារី បារីស៊ីហ្គា និងបារីអេឡិចត្រូនិកគ្រប់ប្រភេទ។

២-អាករ សំដៅដល់ អាករសម្រាប់បំភ្លឺសាធារណៈ។

៣-បុគ្គលជាប់អាករ សំដៅដល់ អ្នកផលិត ឬអ្នកនាំចូលផលិតផលជាប់អាករ ហើយធ្វើការផ្គត់ផ្គង់នៅក្នុងព្រះរាជាណាចក្រកម្ពុជា។ សម្រាប់គោលដៅនៃកថាខណ្ឌនេះ៖

ក- អ្នកផលិត សំដៅដល់ ម្ចាស់ផលិតផលដែលផលិតផលិតផលជាប់អាករដោយខ្លួនឯង ឬដែលជួលបុគ្គលដទៃទៀតឱ្យផលិតផលិតផលជាប់អាករឱ្យខ្លួន។

ខ- អ្នកនាំចូល សំដៅដល់ ម្ចាស់ផលិតផលដែលនាំចូលផលិតផលជាប់អាករដោយខ្លួនឯង ឬដែលប្រគល់សិទ្ធិឱ្យបុគ្គលដទៃទៀតនាំចូលផលិតផលជាប់អាករឱ្យខ្លួន។

**ប្រការ៤ .-**

អាករសម្រាប់បំភ្លឺសាធារណៈ ត្រូវកំណត់តាមអត្រា ៥ (ប្រាំ) ភាគរយ នៃមូលដ្ឋានគិតអាករ។

**ប្រការ៥ .-**

មូលដ្ឋានគិតអាករសម្រាប់បំភ្លឺសាធារណៈ គឺជាថ្លៃផ្គត់ផ្គង់កត់ត្រាលើវិក្កយបត្ររួមបញ្ចូលទាំងពន្ធអាករនានា វៀរលែងតែអាករលើតម្លៃបន្ថែម និងអាករសម្រាប់បំភ្លឺសាធារណៈខ្លួនឯង។

**ប្រការ៦ .-**

១- អាករសម្រាប់បំភ្លឺសាធារណៈ ត្រូវដល់កំណត់និងត្រូវបង់តែម្តងគត់នៅពេលផ្គត់ផ្គង់ផលិតផលជាប់អាករដំបូងបន្ទាប់ពីផលិត ឬនាំចូលក្នុងព្រះរាជាណាចក្រកម្ពុជា។

២- ការផ្គត់ផ្គង់ផលិតផលជាប់អាករ ដែលកែច្នៃពីផលិតផលដែលបានបង់អាករសម្រាប់បំភ្លឺសាធារណៈរួចហើយ ត្រូវចាត់ទុកថាជាការផ្គត់ផ្គង់ដំបូងបន្ទាប់ពីផលិត។

៣-វិធាននៃការផ្គត់ផ្គង់ ត្រូវអនុវត្តស្របតាមវិធាននៃការផ្គត់ផ្គង់សម្រាប់អាករលើតម្លៃបន្ថែម ដូចមានចែងក្នុងកថាខណ្ឌទី១ ដល់កថាខណ្ឌទី៤ នៃមាត្រា៦១ នៃច្បាប់ស្តីពីសារពើពន្ធ។

**ប្រការ៧ .-**

១- បុគ្គលជាប់អាករត្រូវតែជាអ្នកជាប់ពន្ធតាមរបបស្វ័យប្រកាស។

២- អ្នកទទួលសិទ្ធិផលិត ឬនាំចូលផលិតផលជាប់អាករឱ្យបុគ្គលជាប់អាករ ត្រូវបំពេញកាតព្វកិច្ចដូចខាងក្រោម៖

ក- ផ្តល់ព័ត៌មានមកអគ្គនាយកដ្ឋានពន្ធដារដោយភ្ជាប់មកជាមួយនូវលិខិតប្រគល់សិទ្ធិ កិច្ចសន្យាផលិត ឬនាំចូល ជាមួយបុគ្គលជាប់អាករ មុនពេលធ្វើការផលិត ឬនាំចូលផលិតផលជាប់អាករ។

ខ- បញ្ឈប់ការផលិត ឬនាំចូលផលិតផលជាប់អាករ នៅពេលទទួលបាននូវការជូនដំណឹងពីអគ្គនាយកដ្ឋានពន្ធដារស្តីពីការមិនបានបំពេញកាតព្វកិច្ចត្រឹមត្រូវរបស់បុគ្គលជាប់អាករ។

គ- ត្រូវបានចាត់ទុកជាបុគ្គលជាប់អាករ និងទទួលខុសត្រូវបង់ប្រាក់អាករស្របតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន ក្នុងករណីមិនបានបំពេញតាមលក្ខខណ្ឌដូចមានចែងក្នុងវាក្យខណ្ឌ ក និងវាក្យខណ្ឌ ខ នៃកថាខណ្ឌនេះ។

**ប្រការ៨ .-**

បុគ្គលជាប់អាករ ត្រូវមានកាតព្វកិច្ចដាក់លិខិតប្រកាសនិងបង់ប្រាក់អាករសម្រាប់បំភ្លឺសាធារណៈ ជារៀងរាល់ខែ យ៉ាងយឺតបំផុតត្រឹមថ្ងៃទី២០នៃខែបន្ទាប់ពីខែដែលផលិតផលត្រូវបានផ្គត់ផ្គង់។

**ប្រការ៩ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ១០ .-**

រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី នាយកខុទ្ទកាល័យ អគ្គលេខាធិការ ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋាន ឬអគ្គនាយកនៃគ្រប់អគ្គនាយកដ្ឋាន អគ្គាធិការនៃអគ្គាធិការដ្ឋាន និងប្រធានអង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃទី១ ខែមេសា ឆ្នាំ២០២៤ តទៅ។

ថ្ងៃ ពុធ ១១កើត ខែ ផល្គុន ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២០ ខែ មីនា ឆ្នាំ២០២៤

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន

**កន្លែងទទួល៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- រដ្ឋបាលរាជធានី-ខេត្ត
- ដូចប្រការ១០ "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ